ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម

លេខ : ៥៥១ PEAC.អក

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែមេសា ឆ្នាំ 2016

# សេចក្តីជូនដំណឹង

ស្តីពី

ការសាងសង់បណ្តាញ 22kV ចំនួន 02 ខ្សែ ចេញពីអនុស្ថានីយថ្មី
មករោងចក្រ 10 MW និង ប.ត 99 ជូនអគ្គិសនីសៀមរាប

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការសាងសង់បណ្តាញ 22kV ចំនួន 02 ខ្សែ ចេញពីអនុស្ថានីយថ្មីមករោងចក្រ 10 MW និង ប.ត 99 ជូនអគ្គិសនីសៀមរាប ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋានៈ អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី 22 ខែ មេសា ឆ្នាំ 2016 តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ៖ 023 67 66 007 និង Website : www.edc.com.kh) ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី 17 ខែឧសភា ឆ្នាំ 2016 វេលាម៉ោង 14:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង 15:00 ថ្ងៃទី 17 ខែឧសភា ឆ្នាំ 2016 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ចម្លងជូន ៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ